រដ្ឋបាលព្រៃឈើ

គំរោងអភិវឌ្ឍន៍កម្មវិធីព្រៃឈើជាតិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សេចក្តីប្រកាសពត៌មានស្តីពី**

**ការពិគ្រោះយោបល់លើឯកសារកម្មវិធីព្រៃឈើជាតិ**

រដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមជាមួយនឹងភាគីពាក់ព័ន្ធបាននិងកំពុងដំណើរការរៀបចំចងក្រងកម្មវិធីព្រៃឈើជាតិ សំដៅធ្វើយ៉ាងណាសំរេចឱ្យបាននូវការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។ កម្មវិធីព្រៃឈើជាតិឆ្លើយតបទៅនឹងតំរូវការថ្នាក់មូលដ្ឋាន ជាតិ និង អន្តរជាតិក្នុងការរៀបចំឱ្យមានកម្មវិធីគ្រប់គ្រងជាយុទ្ធសាស្ត្រប្រកបដោយតម្លាភាពនិងប្រសិទ្ធិភាពខ្ពស់ ដែលក្នុងដំណើរការនេះរួមមានទាំងការរៀបចំផែនការ ការគ្រប់គ្រង ការប្រើប្រាស់ ការការពារ និងការទាញយកផលប្រយោជន៍ដោយចិរភាព សំរាប់សង្គមមនុស្សនាពេលបច្ចុប្បន្ន និងតទៅអនាគត។

ក្រុមការងារមួយ ដែលមានតំណាងពី រដ្ឋបាលព្រៃឈើ ក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិលក្រៅរដ្ឋាភិបាល និងវិស័យឯកជនត្រូវបានបង្កើតឡើងដើម្បីរួមគ្នាអភិវឌ្ឍកម្មវិធីព្រៃឈើជាតិនេះ ឱ្យក្លាយជាឯកសារគោលសំរាប់ការគ្រប់គ្រងព្រៃឈើដោយចិរភាព ដែលរួមមានកម្មវិធីការងារជាអទិភាពចំនួនប្រាំមួយសំខាន់ៗ។ កម្មវិធីការងារទាំងនោះរួមមាន ១. កម្មវិធី កំណត់ព្រំប្រទល់ដែនព្រៃឈើ ២. កម្មវិធី គ្រប់គ្រង និងអភិរក្សព្រៃឈើ ៣. កម្មវិធី ពង្រឹងការអនុវត្តច្បាប់ និងអភិបាលកិច្ច ៤. កម្មវិធី សហគមន៍ព្រៃឈើ ៥. កម្មវិធី កសាងសមត្ថភាព និងស្រាវជ្រាវ និង ៦. កម្មវិធី វិនិយោគទុន។ ការពិគ្រោះយោបល់ជាសាធារណៈលើសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិនេះ នឹងត្រូវធ្វើឡើងក្នុង ខែ មិនា ឆ្នាំ២០០៩ តាមកាលបរិច្ឆេទដូចខាងក្រោម:

| **អធិការដ្ឋាន** | **ខេត្ត** | **ទីតាំង** | **កាលបរិច្ឆេទ** |
|---|---|---|---|
| អធិការដ្ឋានរដ្ឋបាលព្រៃឈើឈូងសមុទ្រ | ព្រះសីហនុ | ឆ្នេរខ្សាច់មាស | ១៦-១៧ ខែ មិនា |
| អធិការដ្ឋានរដ្ឋបាលព្រៃឈើខាងត្បូងបឹងទន្លេសាប | ពោធិ៍សាត់ | មជ្ឈមណ្ឌលអភិវឌ្ឍន៍<br>ប៊ុន រ៉ានី ហ៊ុន សែន ខេត្តពោធិសាត់ | ១៩-២០ ខែ មិនា |
| អធិការដ្ឋានរដ្ឋបាលព្រៃឈើមេគង្គ | ក្រចេះ | សាលមហោស្រព ខេត្ត | ២៥-២៦ ខែ មិនា |
| អធិការដ្ឋានរដ្ឋបាលព្រៃឈើខាងជើងបឹងទន្លេសាប | សៀមរាប | សាលប្រជុំសាលាខេត្ត | ៣០-៣១ ខែ មិនា |

សិក្ខាសាលាពិគ្រោះយោបល់នេះនឹងត្រូវរៀបចំឡើងដោយអធិការដ្ឋានរដ្ឋបាលព្រៃឈើ ក្រោមជំនួយឧបត្ថម្ភថវិកាពីអន្តរជាតិនានា ជាពិសេស អង្គការ Danida/Dfid/NZAid និង FAO ក្នុងគោលបំណងដើម្បីស្រង់ និង ប្រមូលយកនូវមតិកែលំអរលើសេចក្តីព្រាងកម្មវិធីព្រៃឈើជាតិ ដោយមានការអញ្ជើញចូលរួមពីសំណាក់ ភាគីពាក់ព័ន្ធនានានៅថ្នាក់ក្រោមជាតិ និង មូលដ្ឋាន ដូចជាសហគមន៍មូលដ្ឋាន អាជ្ញាធរដែនដី មន្ទីរអង្គភាពពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និង វិស័យឯកជន សរុបចំនួន ១៥០ នាក់នៅតាមទីតាំងនិមួយៗ។

ប្រសិនបើមានមតិ ឬចំងល់ផ្សេងៗសូមទំនាក់ទំនងទៅកាន់រដ្ឋបាលព្រៃឈើ ដែលមានអាស័យដ្ឋានអាគារលេខ ៤០ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ តាមរយៈលេខ ០១២ ៦៣៩៩៦១។